**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**សាលាខេត្តក្រចេះ**
លេខ ១០៤ សសរ.ក្រច

# សេចក្តីសម្រេច
# ស្តីពី
# ការរៀបចំយន្តការគាំទ្រការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលខេត្តក្រចេះ

## អភិបាលនៃគណៈអភិបាលខេត្តក្រចេះ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការ ជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦៤៧ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ខេត្តក្រចេះ ក្នុងអណត្តិទី២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤០៥ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ
- យោងឯកសារ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩) ដែលបានអនុម័ត និងដាក់អោយប្រើប្រាស់ដោយរាជរដ្ឋាភិបាលនៅថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១០

- យោងឯកសារផែនការអនុវត្តបីឆ្នាំដំណាក់កាលទី២ (២០១៥-២០១៧) នៃ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងសេចក្តីណែនាំលេខ ០២៤ ស.ណ.ន/គ.ជ.អ.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការរៀបចំយន្តការគាំទ្រការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងស្មារតីនៃកិច្ចប្រជុំវិសាមញ្ញលើកទី១០ របស់ក្រុមប្រឹក្សាខេត្តក្រចេះ អាណត្តិទី២ ឆ្នាំទី២ នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៥

## **<u>សម្រេច</u>**

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យដំណើរការនូវមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តក្រចេះ ដើម្បីអភិវឌ្ឍសមត្ថភាពរដ្ឋបាលខេត្តក្រចេះ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងខេត្តក្រចេះ។

**ប្រការ ២.-**

មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តក្រចេះ រួមមានគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សមួយ និងក្រុមការងារបច្ចេកទេសមួយជាជំនួយការ។

**ប្រការ ៣.-**

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| លោក | **ម៉ែន លីណាត** | អភិបាលរងនៃគណៈអភិបាលខេត្ត | ប្រធាន |
| ឯកឧត្តម | **បោប បូផារិទ្ធ** | សមាជិកក្រុមប្រឹក្សាខេត្ត | សមាជិក |
| លោកជំទាវ | **សា ចាន់ហ៊ាង** | សមាជិកាក្រុមប្រឹក្សាខេត្ត | សមាជិកា |
| លោក | **ហង់ មន្ថីរ** | នាយករងរដ្ឋបាលសាលាខេត្ត | សមាជិក |
| លោក | **អ៊ឹង ណារ៉ុង** | នាយករងទីចាត់ការគ្រប់គ្រងធនធានមនុស្ស | សមាជិក |
| លោក | **សាម លីម៉េត** | ប្រធានការិយាល័យកសាងសមត្ថភាពនៃទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលាខេត្ត | លេខាធិការ |

**ប្រការ ៤.-**

គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តក្រចេះ មានតួនាទីដឹកនាំ សម្របសម្រួល តាមដានត្រួតពិនិត្យ និងវាយតម្លៃ លើការងារអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រី បុគ្គលិករដ្ឋបាលខេត្តក្រចេះ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងខេត្តក្រចេះ និងមានភារកិច្ចដូចខាងក្រោម៖

- ធានាឱ្យមានការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ន
- ផ្តល់ការណែនាំ ពិនិត្យ និងឯកភាពទៅលើសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាព ដើម្បីដាក់ជូនគណៈអភិបាល និងក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- សម្របសម្រួលសកម្មភាពអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលខេត្តក្រចេះ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងខេត្តក្រចេះ
- ពិនិត្យ ផ្តល់យោបល់ និងឯកភាពលើឯកសារ និងរបាយការណ៍អំពីការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលខេត្តក្រចេះ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងខេត្តក្រចេះ ។
- កៀរគរធនធានសម្រាប់គាំទ្រការងារអភិវឌ្ឍន៍សមត្ថភាពនៅរដ្ឋបាលខេត្តក្រចេះ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងខេត្តក្រចេះ
- ធានាថាការគ្រប់គ្រងហិរញ្ញវត្ថុរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តក្រចេះ អនុវត្តបានត្រឹមត្រូវទៅតាមបែបបទ និងនីតិវិធីដែលបានកំណត់
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តក្រចេះ
- ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាពនៃការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលខេត្តក្រចេះ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងខេត្តក្រចេះ ។
- ធានាឱ្យមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តក្រចេះ មានទីកន្លែងសមស្របសម្រាប់បំពេញការងារ មានឧបករណ៍ សម្ភារគ្រប់គ្រាន់សម្រាប់អនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន មានបន្ទប់ប្រជុំសមស្របសម្រាប់អនុវត្តសកម្មភាពនានា និងមានប្រព័ន្ធផ្តល់ព័ត៌មានទាន់ហេតុការណ៍ និងប្រព័ន្ធទុកដាក់តម្កល់ឯកសារ ។

**ប្រការ ៥._**

គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តក្រចេះ មានរបៀបរបបការងារដូចខាងក្រោម ៖

- គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តក្រចេះ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាខេត្តក្រចេះ និងគណៈអភិបាលខេត្តក្រចេះ ក្នុងការបំពេញការងាររបស់ខ្លួន
- គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តក្រចេះ ត្រូវជួបប្រជុំយ៉ាងតិច០២ខែម្តង និងតាមការចាំបាច់ ដើម្បីតាមដាន ត្រួតពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានា ដែលអាចកើតមាននៅក្នុងការអនុវត្តការងារពាក់ព័ន្ធការអភិវឌ្ឍសមត្ថភាព
- កូរ៉ុមនៃកិច្ចប្រជុំ ត្រូវមានលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការទាំងមូល
- ប្រធានគណៈកម្មាធិការ ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការ ។ ក្នុងករណីប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរទៅឱ្យសមាជិកណាមួយ ជាប្រធានស្តីទី ។

- សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មាធិការអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល ។ ប្រសិនបើសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។
- ប្រធានគណៈកម្មាធិកាត្រូវអញ្ជើញតំណាងក្រុមការងារបច្ចេកទេសចូលរួមប្រជុំនៅគ្រប់កិច្ចប្រជុំរបស់ខ្លួន ។
- ប្រធានគណៈកម្មាធិការអាចអញ្ជើញប្រធានមន្ទីរ អង្គភាពជំនាញ តំណាងរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ អ្នកផ្តល់សេវាកម្មផ្នែកអភិវឌ្ឍន៍សមត្ថភាពនិងអ្នកពាក់ព័ន្ធនានាដើម្បីចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការតាមការចាំបាច់ ។
- គ្រប់កិច្ចប្រជុំរបស់គណៈកម្មាធិការ ត្រូវមានកំណត់ហេតុ ដែលរៀបចំដោយលេខាធិការរបស់គណៈកម្មាធិការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ ។
- ការិយាល័យកសាងសមត្ថភាពនៃទីចាត់ការគ្រប់គ្រងធនធានមនុស្សនៃសាលាខេត្តក្រចេះ ធ្វើជាសេនាធិការជូនគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តក្រចេះ ។

**ប្រការ ៦._**

ក្រុមការងារបច្ចេកទេសរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមុស្សខេត្តក្រចេះ មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១.លោក | អ៊ុំ | ភិណន់ | ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ខេត្ត |
| ២.លោក | អ៊ុក | ពិសិដ្ឋ | ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពខេត្ត |
| ៣.លោក | ម៉ី | កុសល | ទីប្រឹក្សាហិរញ្ញវត្ថុខេត្ត |
| ៤.លោក | ទួន | ស៊ីវ៉ាត់ | ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត |
| ៥.លោកស្រី | ប៊ុច | ច័ន្ទណារី | បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាខេត្ត |
| ៦.លោក | ហោ | ឡារ៉ូ | បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាស្រុក |
| ៧.លោក | ថន | គីមឈន់ | បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សា ក្រុង ស្រុក |
| ៨.លោក | ចាន់ | សុខារិទ្ធ | ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពក្រុង ស្រុក |
| ៩.លោក | ចាប | ទីណាំង | ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពក្រុង ស្រុក |
| ១០.លោក | យ៉ាង | ចិត្រា | បុគ្គលិកព័ត៌មានវិទ្យាខេត្ត |
| ១១.លោកស្រី | សន | សោភា | ជំនួយការការិយាល័យថ្នាក់ខេត្ត |

**ប្រការ ៧._**

ក្រុមការងារបច្ចេកទេស មានតួនាទីអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលខេត្តក្រចេះ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្នុងខេត្តក្រចេះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៅមូលដ្ឋាន និងពីថ្នាក់ជាតិ និងមានភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងគោលបំណង រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងរបៀបទំនាក់ទំនងជាមួយមណ្ឌល ដល់ក្រុមប្រឹក្សា គណៈអភិបាល មន្ត្រីរបស់រដ្ឋបាលខេត្តក្រចេះ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងខេត្តក្រចេះ និងអ្នកពាក់ព័ន្ធនានា
- គាំទ្រដល់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីរបស់រដ្ឋបាលខេត្តក្រចេះ និង រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងខេត្តក្រចេះ ក្នុងការបកស្រាយបំភ្លឺនានាពាក់ព័ន្ធទៅនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ពង្រឹងសមត្ថភាពដល់ការិយាល័យកសាងសមត្ថភាព សំដៅធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រងចាត់ចែងកិច្ចការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឆ្លើយតប
- រៀបចំសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់មណ្ឌលអភិវឌ្ឍធនធានមនុស្សខេត្តក្រចេះ ដើម្បីដាក់ជូនគណៈកម្មាធិការគ្រប់គ្រងមណ្ឌល គណៈអភិបាល និងក្រុមប្រឹក្សាខេត្ត ពិនិត្យ ផ្តល់យោបល់ និងអនុម័ត ។
- ធ្វើការប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍន៍ស្ថាប័ន ការរៀបចំនិងធ្វើបច្ចុប្បន្នភាពផែនការអន្តរាគមន៍អភិវឌ្ឍន៍ស្ថាប័ន ការរៀបចំតាក់តែងនិងផ្តល់កិច្ចអន្តរាគមន៍អភិវឌ្ឍន៍ស្ថាប័ន និង ការវាយតម្លៃលទ្ធផលនៃការអភិវឌ្ឍស្ថាប័ន ស្របតាមខ្លឹមសារនៃសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ធានាឱ្យមានការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធមិសង្គមនៅក្នុងកិច្ចដំណើរការអភិវឌ្ឍន៍សមត្ថភាព រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលអំពីយេនឌ័រ បរិយាប័ន្ន និង សមធមិសង្គមប្រចាំឆ្នាំ ដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលខេត្តក្រចេះ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងខេត្តក្រចេះ
- រៀបចំ និងធ្វើបច្ចុប្បន្នភាពបញ្ជីអ្នកផ្តល់សេវាកម្មផ្នែកអភិវឌ្ឍន៍សមត្ថភាពនៅខេត្តក្រចេះ
- រៀបចំប្រព័ន្ធឆ្លើយតបទាន់ហេតុការណ៍ តាមរយៈការរៀបចំឱ្យមានប្រព័ន្ធទូរស័ព្ទ ទូរសារ និង អាស័យដ្ឋានសារអេឡិចត្រូនិច ប្រព័ន្ធបណ្តាញសង្គម និងគេហទំព័រជាដើម សម្រាប់ទទួល និងឆ្លើយតបទៅនឹងសំណួរ ឬការស្នើសុំបំភ្លឺនានា ពីក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីនៅរដ្ឋបាលខេត្តក្រចេះ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងខេត្តក្រចេះ
- សម្របសម្រួល អនុវត្ត និងផ្តល់កិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពនៅរដ្ឋបាលខេត្ត ដោយប្រើប្រាស់យុទ្ធសាស្ត្រ និងគោលវិធីនៃការអភិវឌ្ឍសមត្ថភាព
- រៀបចំប្រព័ន្ធទុកដាក់ឯកសារទាំងឯកសារអេឡិចត្រូនិច និងឯកសារបោះពុម្ព ដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យអភិវឌ្ឍន៍សមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួលជ្រើសរើសអង្គភាព ឬអ្នកផ្តល់សេវាកម្មអភិវឌ្ឍន៍សមត្ថភាព ក្នុងការផ្តល់កិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពដល់រដ្ឋបាលខេត្តក្រចេះ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងខេត្តក្រចេះ ស្របតាមនីតិវិធីកំណត់

- គាំទ្រដល់ការរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ អំពីលទ្ធផលនៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ព្រមទាំងរៀបចំតារាងបូកសរុបទិន្នន័យ នៃការអភិវឌ្ឍសមត្ថភាព

**ប្រការ ៨._**

ក្រុមការងារបច្ចេកទេសត្រូវបំពេញការងារក្រោមការសម្របសម្រួលពីទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ ខេត្ត និងមានរបៀបរបបការងារ ដូចខាងក្រោម ៖

- ទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តក្រចេះ ក្នុងការបំពេញការងាររបស់ខ្លួនក្នុងក្របខ័ណ្ឌនៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត
- ត្រូវជួបប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ និងតាមការចាំបាច់ក្រោមការសម្របសម្រួលរបស់ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ខេត្ត
- គ្រប់កិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេស ត្រូវមានរបៀបវារៈ និងកំណត់ហេតុ។ កំណត់ហេតុកិច្ចប្រជុំ ត្រូវចម្លងជូនគណៈកម្មាធិការគ្រប់គ្រងមណ្ឌល ០១ច្បាប់។
- សមាជិកក្រុមការងារម្នាក់ៗ ត្រូវរៀបចំផែនការការងារប្រចាំខែ និងរៀបចំរបាយការណ៍លទ្ធផលអនុវត្តការងារប្រចាំខែរបស់ខ្លួន
- ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្រុមការងារបច្ចេកទេសត្រូវធ្វើទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងជាប្រចាំជាមួយការិយាល័យកសាងសមត្ថភាព
- ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្រុមការងារបច្ចេកទេសអាចស្នើសុំមតិយោបល់ពី គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស
- ត្រូវបែងចែកជាពីរក្រុម ដោយមួយក្រុមទទួលខុសត្រូវអភិវឌ្ឍន៍សមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងមួយក្រុមទៀតទទួលខុសត្រូវអភិវឌ្ឍន៍សមត្ថភាពគណៈអភិបាល និងមន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- ត្រូវរៀបចំឱ្យមានទីប្រឹក្សា ឬបុគ្គលិករបស់មណ្ឌលប្រចាំការនៅរៀងរាល់ម៉ោងធ្វើការងារ ដើម្បីទទួល និងឆ្លើយតបទៅនឹងសំណួរ ឬសំណើ សំណូមពរនានារបស់ក្រុមប្រឹក្សា គណៈអភិបាល មន្ត្រី បុគ្គលិករបស់រដ្ឋបាលខេត្តក្រចេះ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងខេត្តក្រចេះ និងអ្នកពាក់ព័ន្ធនានា ពាក់ព័ន្ធទៅនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

**ប្រការ ៩._**

តួនាទី និងភារកិច្ចជាក់លាក់នៃមុខតំណែងនីមួយៗនៅក្នុងក្រុមការងារបច្ចេកទេស មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ។

**ប្រការ ១០._**

រាល់បទប្បញ្ញត្តិទាំងឡាយណារបស់រដ្ឋបាលខេត្តក្រចេះ ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១១._**

ក្រុមប្រឹក្សាខេត្តក្រចេះ គណៈអភិបាលខេត្តក្រចេះ នាយករដ្ឋបាល ទីចាត់ការទាំង៥ និងអង្គភាពលទ្ធកម្ម ចំណុះសាលាខេត្តក្រចេះ រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ក្នុងខេត្តក្រចេះ មន្ទីរ អង្គភាពក្នុងខេត្ត និងឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដូចមានឈ្មោះក្នុងប្រការ៣ ប្រការ៦ និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវទទួលបន្ទុកអនុវត្តន៍សេចក្តីសម្រេចនេះ តាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ក្រចេះ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥

**អភិបាលខេត្ត**

សារ ចំរុង

**កន្លែងទទួល**

-ក្រសួងមហាផ្ទៃ

-លេខាធិការដ្ឋាន គ.ជ.អ.ប

"ដើម្បីជូនជ្រាប"

-ក្រុមប្រឹក្សាខេត្ត

-ដូចប្រការ ១១

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ